# រឿងទី៦៖ អេលីយ៉ា

**ខគម្ពីរ៖**
**១ពង្សាវតាក្សត្រ១៧៖២៤**

ស្ត្រីនោះពោលទៅកាន់លោកអេលីយ៉ាថា៖ «ឥឡូវនេះ នាងខ្ញុំដឹងថា លោកជាអ្នកជំនិតរបស់ព្រះជាម្ចាស់មែន ហើយសេចក្ដីដែលលោកថ្លែងពិតជាព្រះបន្ទូលរបស់ ព្រះអម្ចាស់ »។

នេះគឺជារឿងរ៉ាវពេលដែលស្ដេចអហាប់គ្រប់គ្រងស្រុកអ៊ីស្រាអែល។ ព្រះបាទអហាប់ គឺជាស្ដេចដែលមិនគោរពកោតខ្លាចព្រះជាម្ចាស់ ប៉ុន្តែ ទ្រង់គោរពបម្រើព្រះបាលវិញ។
នៅសម័យនោះ ព្រះជាម្ចាស់បានបញ្ជូនព្យាការីអេលីយ៉ាឱ្យមកប្រជាជនអ៊ីស្រាអែល។
លោកអេលីយ៉ា គឺជាអ្នកប្រកាសព្រះបន្ទូលព្រះជាម្ចាស់ដល់រាស្ត្រអ៊ីស្រាអែល។
មានថ្ងៃមួយ ព្រះជាម្ចាស់បានចេញបង្គាប់ឱ្យលោកអេលីយ៉ាធ្វើដំណើរទៅក្រុងសារិបតា។
ទ្រង់បានមានបន្ទូលប្រាប់ថាលោកនឹងជួបនិងស្ត្រីមេម៉ាយម្នាក់នៅទីនោះ។
ពេលនោះ លោកអេលីយ៉ាងក៏បានជួបស្ត្រីម្នាក់កំពុងតែរើសអុស។ ស្ត្រីម្នាក់នោះហើយដែលជាស្ត្រីមេម៉ាយម្នាក់នោះ។
លោកអេលីយ៉ាបាននិយាយទៅកាន់ស្ត្រីនោះថា៖ «តើខ្ញុំអាចសុំទឹកផឹក និងនំប៉័ងមួយដុំបានទេ?»
ស្ត្រីមេម៉ាយនោះ បានដឹងថាលោកអេលីយ៉ាគឺជាមនុស្សដែលព្រះជាម្ចាស់បានបញ្ជូនមកតាំងពីឃើញដំបូង។
ប៉ុន្តែ ដោយព្រោះស្ត្រីមេម៉ាយនោះក្រខ្សត់ខ្លាំងពេក ដូច្នេះ សំណើររបស់លោកអេលីយ៉ាពេលនោះ វាពិតជាពិបាកណាស់សម្រាប់នាង។
ប៉ុន្តែទោះជាយ៉ាងណា ស្ត្រីមេម៉ាយនោះ នៅតែធ្វើតាមការចង់បានរបស់លោកអេលីយ៉ា។
ដូច្នេះនៅពេលនោះ ចាប់តាំងពីថ្ងៃនោះរហូតដល់គ្រោះរាំងស្ងួតនៅអ៊ីស្រាអែលបីឆ្នាំបានបញ្ចប់ ពួកគេមានអាហារបរិភោគ រាល់ថ្ងៃ ម្សៅមិនចេះអស់ពីខាប់ ប្រេងក៏មិនចេះអស់ពីដបដែរ។
ព្រះពរដ៏អស្ចារ្យរបស់ព្រះជាម្ចាស់បានកើតមាននៅក្នុងផ្ទះស្ត្រីមេម៉ាយនៅក្រុងសារិបតានោះ។
ប៉ុន្តែ មានថ្ងៃមួយ មានរឿងសោកសៅមួយបានកើតមានក្នុងផ្ទះរបស់ស្ត្រីមេម៉ាយនោះ។
គឺកូនប្រុសដែលធ្លាប់តែមានសុខភាពល្អ ក៏ចាប់ធ្លាក់ខ្លួនឈឺធ្ងន់ រហូតដល់ផុតដង្ហើមភ្លាមៗ។ ស្ត្រីមេម៉ាយបានយំបោកខ្លួន។
លោកអេលីយ៉ាបានយកកូនប្រុសដែលបានស្លាប់នោះទៅបន្ទប់ខាងលើ ផ្ដេកនៅលើគ្រែ រួចលោកបានអធិស្ឋានទៅ ព្រះជាម្ចាស់។
ព្រះជាម្ចាស់បានឆ្លើយតបការអធិស្ឋានរបស់លោកអេលីយ៉ា។
ទ្រង់បានសង្គ្រោះកូនដែលស្លាប់នោះឱ្យរស់ឡើងវិញម្ដងទៀត។
ស្ត្រីមេម៉ាយបានឱបកូនដែលរស់ឡើងវិញនោះ ហើយយំជាខ្លាំង។
ស្ត្រីមេម៉ាយនោះបានអរព្រះគុណដល់ព្រះជាម្ចាស់។





## សកម្មភាពទី១

ចូលបិទសំឡីនៅលើក្អមម្សៅ ហើយបិទក្រដាសពណ៌លឿងនៅលើក្អមប្រេង។

សម្ភារៈ៖ សំឡី, ក្រដាសពណ៌លឿង, កាវ, កន្ត្រៃ



**សកម្មភាពទី២** សូមគិតអំពីខ្លឹមសារមេរៀនដែលបានរៀនថ្ងៃនេះ រួចផាត់ពណ៌រូបភាពខាងក្រោម។



- សូមសរសេរតាមខគម្ពីរខាងក្រោម រួចទន្ទេញ។ (១ពង្សាវតាក្សត្រ១៧:២៤)

ខ្ញុំដឹងថា លោកជាអ្នកជំនិតរបស់ព្រះជាម្ចាស់មែន